Anti-Racism Policy
Information for parents and carers

# គោលនយោបាយប្រឆាំងការរើសអើងជាតិសាសន៍

## ព័ត៌មានសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ

ការរើសអើងជាតិសាសន៍ប៉ះពាល់ដល់សុខុមាលភាព ការចូលរួមនៅសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ការប្រកាន់ជាតិសាសន៍ និងអាកប្បកិរិយាប្រកាន់ពូជសាសន៍ មិនត្រូវបានអត់ឱនឡើយនៅសាលារៀនរដ្ឋនៅរដ្ឋ NSW។

## តើគោលនយោបាយនិយាយអំពីអ្វី?

Anti-Racism Policy (គោលនយោបាយប្រឆាំងការរើសអើងជាតិសាសន៍) លើកកម្ពស់ការគោរព និងភាពចុះសម្រុងគ្នានៅក្នុងបរិយាកាសសាលា។ វាមានគោលបំណងធានាថា ឱកាសអប់រំនានាមានភាពត្រឹមត្រូវសម្រាប់សិស្សទាំងអស់ ដោយមិនគិតពីវប្បធម៌ ភាសា ឬប្រវត្តិសាសនារបស់ពួកគេឡើយ។ គោលនយោបាយ៖

- ទទួលស្គាល់ផលប៉ះពាល់នៃការរើសអើងជាតិសាសន៍លើជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait
- ធានាថាសាលារៀនមានការរំពឹងទុកខ្ពស់របស់សិស្សទាំងអស់ ហើយថាគ្មានសិស្សមួយក្រុមណាមួយ ត្រូវបានឃាត់ឃាំងពីការឈានដល់សក្តានុពលពេញលេញរបស់ពួកគេ ដោយព្រោះតែប្រវត្តិវប្បធម៌ សាសនា ឬភាសារបស់ពួកគេនោះទេ
- តម្រូវឱ្យសមាជិកទាំងអស់នៃសហគមន៍សាលារៀន គិតអំពីអាកប្បកិរិយារបស់ពួកគេ ហើយត្រូវប្រាកដថាសកម្មភាពនានារបស់ពួកគេ មិនបណ្តាលឱ្យមនុស្សផ្សេងទៀតជួបប្រទះការរើសអើងជាតិសាសន៍ទេ
- តម្រូវឱ្យបុគ្គលិកទាំងអស់បំពេញការបណ្តុះបណ្តាល ដើម្បីឱ្យពួកគេយល់ដឹងពីទំនួលខុសត្រូវរបស់ពួកគេ ក្នុងការទប់ស្កាត់ការរើសអើងជាតិសាសន៍
- តម្រូវឱ្យសាលារៀននីមួយៗមាន មន្ត្រីទំនាក់ទំនងប្រឆាំងការរើសអើងជាតិសាសន៍ដែលបានបណ្តុះបណ្តាល។

## តើមន្ត្រីទំនាក់ទំនងប្រឆាំងការរើសអើងជាតិសាសន៍ជានរណា?

មន្ត្រីទំនាក់ទំនងប្រឆាំងការរើសអើងជាតិសាសន៍ (Anti-Racism Contact Officer (ARCO)) គឺជាគ្រូបង្រៀនម្នាក់ដែលត្រូវបានតែងតាំងដោយនាយកសាលា ដែលជួយក្នុងការដឹកនាំការអប់រំអំពីការប្រឆាំងការរើសអើងជាតិសាសន៍នៅសាលារៀន។ ARCO ជួយដល់នាយកសាលាដោយផ្តល់៖

- ការគាំទ្រដើម្បីកសាងការយល់ដឹងរបស់បុគ្គលិក អំពីផលប៉ះពាល់នៃការរើសអើងជាតិសាសន៍លើការសិក្សា និងសុខុមាលភាពរបស់សិស្ស
- ដំបូន្មានដល់សិស្ស និងបុគ្គលិកអំពីរបៀបឆ្លើយតបនៅពេលពួកគេឃើញ ឬឮអំពីឧប្បត្តិហេតុនៃការរើសអើងជាតិសាសន៍
- ដំបូន្មានអំពីយុទ្ធសាស្ត្រអ្វីខ្លះដែលសាលារៀនអាចអនុវត្ត ដើម្បីដោះស្រាយការរើសអើងជាតិសាសន៍។

ARCO ត្រូវបានបណ្តុះបណ្តាលដើម្បីផ្តល់ដំបូន្មានដល់ឪពុកម្តាយ និងអ្នកថែទាំ គ្រូបង្រៀន និងសិស្សអំពីនីតិវិធីសម្រាប់ការដោះស្រាយ reports (របាយការណ៍) អំពីការរើសអើងជាតិសាសន៍។ ប្រសិនបើត្រូវបានស្នើសុំ ARCO ក៏អាចបំពេញតួនាទីជា support person or advocate (អ្នកគាំទ្រ ឬអ្នកតស៊ូមតិ) ក្នុងអំឡុងដំណើរការផងដែរ។

## តើខ្ញុំគួរធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំកំពុងជួបប្រទះការរើសអើងជាតិសាសន៍នៅសាលារៀន?

ប្រសិនបើកូនរបស់អ្នកកំពុងជួបប្រទះការរើសអើងជាតិសាសន៍នៅសាលារៀន អ្នកគួរតែលើកទឹកចិត្តពួកគេឱ្យរាយការណ៍ទៅគ្រូបង្រៀន ឬមន្ត្រីទំនាក់ទំនងប្រឆាំងការរើសអើងជាតិសាសន៍របស់សាលារៀន ឬអ្នកអាចរាយការណ៍អំពីហេតុការណ៍នោះជំនួសកូនរបស់អ្នកបានដែរ។

## តើខ្ញុំធ្វើរបាយការណ៍អំពីការរើសអើងជាតិសាសន៍នៅសាលារៀនដោយរបៀបណា?

សមាជិកណាម្នាក់នៃសហគមន៍សាលារៀន រួមទាំងឪពុកម្ដាយ និងអ្នកថែទាំ និងបុគ្គលិក និងសិស្សអាចធ្វើ report (របាយការណ៍) អំពីការរើសអើងជាតិសាសន៍បាន។ របាយការណ៍អំពីការរើសអើងជាតិសាសន៍អាចធ្វើទៅនាយកសាលា មន្ត្រីទំនាក់ទំនងប្រឆាំងការរើសអើងជាតិសាសន៍ ឬសមាជិកបុគ្គលិកណាម្នាក់។ របាយការណ៍នានាអាចធ្វើឡើងដោយផ្ទាល់ តាមអ៊ីមែល ឬទូរសព្ទ និងតាមអនឡាញផងដែរ ដោយប្រើ feedback and complaint form (ទម្រង់បែបបទមតិកែលម្អ និងបណ្ដឹងតវ៉ា) របស់ក្រសួង។

## ចុះយ៉ាងណាដែរអំពីការរើសអើងជាតិសាសន៍តាមអនឡាញ?

ការរើសអើងជាតិសាសន៍ទាក់ទងនឹងសាលារៀន ដែលកើតមានឡើងតាមអនឡាញ ដូចជាពួកសិស្សតម្រង់សំដៅការរើសអើងជាតិសាសន៍ទៅរកសិស្សម្នាក់ៗ ឬក្រុមវប្បធម៌ គួរតែបានរាយការណ៍ទៅសាលារៀនដូចមានចែងខាងលើ។ សម្រាប់ដំបូន្មានអំពីរបៀបរក្សាសុវត្ថិភាពតាមអនឡាញ សូមមើល Online safety (សុវត្ថិភាពតាមអនឡាញ) នៅលើគេហទំព័រ eSafety Commissioner website (គេហទំព័រស្នងការសុវត្ថិភាព eSafety)។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅឯណា?

សម្រាប់ព័ត៌មានបន្ថែម សូមមើល Anti-racism education (ការអប់រំអំពីការប្រឆាំងការរើសអើងជាតិសាសន៍)។

## ជំនួយអ្នកបកប្រែផ្ទាល់មាត់

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយនិយាយទៅកាន់សាលារៀន ឬធ្វើការណាត់ជួបជាមួយបុគ្គលិកម្នាក់ សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់ តាមលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។

សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទរបស់សាលារៀន ពេលនោះការីទូរសព្ទនឹងទូរសព្ទទៅសាលារៀន ហើយរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកក្នុងការសន្ទនារបស់អ្នក។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ក្នុងអំឡុងពេលប្រជុំជាមួយបុគ្គលិកសាលា សូមស្នើសុំឱ្យសាលារៀនរៀបចំជូនអ្នក។ សាលារៀននឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់នៅនឹងកន្លែង ឬក៏តាមទូរសព្ទ អាស្រ័យលើភាពអាចរកបាន។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មបកប្រែផ្ទាល់មាត់ទេ។